អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

Kingdom of Cambodia
Nation Religion King

Royaume du Cambodge
Nation Religion Roi

ថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០១១

# សេចក្តីប្រកាសព័ត៌មាន

## អង្គជំនុំជម្រះសាលាដំបូងប្រកាសកាលបរិច្ឆេទបើកសវនាការលើអង្គសេចក្តី នៅក្នុងសំណុំរឿង ០០២

អង្គជំនុំជម្រះសាលាដំបូងសូមប្រកាសនៅថ្ងៃនេះថា សវនាការលើអង្គសេចក្តីដើម្បីជំនុំជម្រះសំណុំរឿង ០០២ នឹងចាប់ផ្តើមធ្វើនៅថ្ងៃច័ន្ទ ទី២១ ខែវិច្ឆកា ឆ្នាំ២០១១ វេលាម៉ោង ៩ ព្រឹក នៅសាលសវនាការនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) និងបន្តធ្វើនៅថ្ងៃបន្តបន្ទាប់ទៀត។ សវនាការពិនិត្យលើភ័ស្តុតាងនៅក្នុងសំណុំរឿងនេះ នឹងចាប់ផ្តើមធ្វើនៅថ្ងៃច័ន្ទ ទី២៨ ខែវិច្ឆកា ឆ្នាំ២០១១។ ការបើកសវនាការលើអង្គសេចក្តីនេះ ត្រូវបានធ្វើឡើងបន្ទាប់ពីអង្គជំនុំជម្រះសាលាដំបូងបានធ្វើសវនាការបឋមលើសំណុំរឿង ០០២ នេះ កាលពីថ្ងៃទី ២៧ រហូតដល់ថ្ងៃទី ៣០ ខែមិថុនា ឆ្នាំ២០១១ កន្លងទៅ ស្របតាមវិធានផ្ទៃក្នុងរបស់ អ.វ.ត.ក។

សវនាការនៅថ្ងៃច័ន្ទ ទី២១ ខែវិច្ឆកា ឆ្នាំ២០១១ ខាងមុខនេះ នឹងចាប់ផ្តើមធ្វើឡើងដោយការអាននូវបទចោទប្រកាន់ទាំងឡាយប្រឆាំងនឹងជនជាប់ចោទម្នាក់ៗ។ បន្ទាប់មក សហព្រះរាជអាជ្ញានឹងត្រូវបានផ្តល់ជូននូវរយៈពេល២(ពីរ)ថ្ងៃ ដើម្បីធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ប្រឆាំងនឹងជនជាប់ចោទ។ ទោះបីជាពេលថ្មីៗនេះ អង្គជំនុំជម្រះសាលាដំបូងបានបំបែកកិច្ចដំណើការនីតិវិធីនៅក្នុងសំណុំរឿង ០០២ ជាផ្នែកតូចៗដើម្បីជំនុំជម្រះយ៉ាងណាក៏ដោយ ក៏ការជំនុំជម្រះលើកដំបូងនេះនឹងផ្តល់ជាមូលដ្ឋានគ្រឹះរួមសម្រាប់បទចោទប្រកាន់ទាំងឡាយប្រឆាំងនឹងជនជាប់ចោទ រួមទាំងបទចោទប្រកាន់ដែលនឹងត្រូវយកមកដេញដោលនៅក្នុងពេលជំនុំជម្រះលើកក្រោយៗទៀតផង។ ហេតុដូច្នេះសហព្រះរាជអាជ្ញានឹងធ្វើសេចក្តីសន្និដ្ឋានចោទប្រកាន់ទាក់ទងនឹងបទចោទប្រកាន់ទាំងអស់ និងអង្គហេតុដែលបានចោទប្រកាន់ទាំងអស់ ប្រឆាំងនឹងជនជាប់ចោទនៅក្នុងសំណុំរឿង ០០២។ សហមេធាវីតំណាងជនជាប់ចោទនីមួយៗនឹងត្រូវបានផ្តល់ជូននូវឱកាសដើម្បីធ្វើការឆ្លើយតបទៅ

នឹងសេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញា។ សហមេធាវីតំណាងជនជាប់ចោទនីមួយៗនឹងត្រូវបានផ្តល់ជូននូវពេលវេលាកន្លះថ្ងៃ ដើម្បីធ្វើការឆ្លើយតបទៅនឹងសេចក្តីសន្និដ្ឋានចោទប្រកាន់របស់សហព្រះរាជអាជ្ញាប្រឆាំងនឹងកូនក្តីរបស់ខ្លួន។

បន្ទាប់ពីការបើកសេចក្តីសន្និដ្ឋានចោទប្រកាន់ និងការឆ្លើយតបត្រូវបានបញ្ចប់ សវនាការដើម្បីពិនិត្យលើភ័ស្តុតាងនៅក្នុងសំណុំរឿង ០០២ នឹងចាប់ផ្តើមធ្វើពីថ្ងៃច័ន្ទ ទី២៨ ខែវិច្ឆិកា ឆ្នាំ២០១១ វេលាម៉ោង ៩ ព្រឹក។ វគ្គដំបូងនៃការជំនុំជម្រះនេះនឹងត្រូវបញ្ចប់យ៉ាងយូរត្រឹមថ្ងៃសុក្រ ទី១៦ ខែធ្នូ ឆ្នាំ២០១១ ហើយបន្ទាប់ពីពេលនេះ អង្គជំនុំជម្រះនឹងឈប់សម្រាកសម្រាប់បុណ្យណូអែលនិងបុណ្យចូលឆ្នាំសកល។ បន្ទាប់ពីការឈប់សម្រាកនេះ អង្គជំនុំជម្រះសាលាដំបូងនឹងបន្តសវនាការចាប់ពីថ្ងៃច័ន្ទ ទី៩ ខែមករា ឆ្នាំ២០១២។ ការជំនុំជម្រះរបស់អង្គជំនុំជម្រះសាលាដំបូងនឹងត្រូវធ្វើឡើងជាសាធារណៈឲ្យបានច្រើនបំផុត តាមដែលអាចធ្វើទៅបាន។

អង្គជំនុំជម្រះសាលាដំបូងនឹងជូនព័ត៌មានបន្ថែមទៀតទាក់ទងនឹងការកំណត់ពេលវេលានៃ ការជំនុំជម្រះនៃវគ្គក្រោយៗទៀតក្នុងថិរៈវេលាមួយសមស្រប។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖

**លោក ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
ទូរសព្ទដៃ៖ +៨៥៥(0)១២ ៤៨៨ ០២៣
ទូរសព្ទ៖+៨៥៥(0)២៣ ២១៩ ៨៤១ លេខបន្ត ៦១៦៩
សារអេឡិចត្រូនិក៖ olsenl@un.org

**លោក នេត្រ ភក្ត្រា**
មន្ត្រីនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរសព្ទដៃ៖ +៨៥៥(0)១២ ៤៨៣ ២៨៣
សារអេឡិចត្រូនិក៖ neth.pheaktra@eccc.gov.kh